ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# កិច្ចប្រជុំបណ្តាញអ្នកផ្តល់ប្រឹក្សាផ្នែកថែទាំ ព្យាបាលជំងឺអេដស៍ លើមនុស្សពេញវ័យ ប្រចាំតំបន់លើកទី ៧



## The 7th Regional Network Meeting on OI/ART for Counselor for Adult

Kampot Province, 16 - 18 Aug, 2011

Prepared by

Supported by

របាយការណ៍

# កិច្ចប្រជុំបណ្តាញអ្នកផ្តល់ប្រឹក្សាផ្នែកថែទាំ ព្យាបាលជំងឺអេដស៍ លើមនុស្សពេញវ័យ ប្រចាំតំបន់កំពង់សោមលើកទី ៧

## The 7th Regional Network Meeting for Pediatric Counseling on Management of OI/ART for Nurses

១. ទីកន្លែងបណ្តុះបណ្តាល: សាលប្រជុំមន្ទីរសុខាភិបាលខេត្ត កំពត

២. កាលបរិច្ឆេទ: ថ្ងៃទី ១៦ - ១៨ ខែ សីហា ឆ្នាំ ២០១១

៣. គោលបំណងនៃសិក្ខាសាលា:

- ការបង្ហាញពីបច្ចុប្បន្នភាពនៃគំរោងថែទាំបន្ត ប្រចាំប្រទេសកម្ពុជា
- ការបង្ហាញពីប្រធានបទថ្មីៗ ស្តីពីការផ្តល់ប្រឹក្សាអ្នកជំងឺអេដស៍
- ការបង្ហាញពីករណីសិក្សាដែលអ្នកផ្តល់ប្រឹក្សាបានជួបប្រទះ
- ការពិភាក្សាពីបញ្ហានានា ជុំវិញការផ្តល់ប្រឹក្សា

៤. រៀបចំដោយ: មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

៥. ឧបត្ថម្ភដោយ: GFATM

៦. សកម្មភាពកិច្ចប្រជុំ:

ថ្ងៃទី ១ : ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១១

ពេលព្រឹក:

- ការអញ្ជើញមកដល់និងការចុះវត្តមានរបស់សិក្ខាកាម និងគណ:អធិបតី
- គណ:គណអធិបតីក្នុងពិធីបើក និងបិទកិច្ចប្រជុំ

| | |
|---|---|
| •លោកវេជ្ជ. អ៊ុំ សុខុម | អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| •លោកវេជ្ជ. ញ៉ា ម៉ុនថន | ប្រធានមន្ទីរសុខាភិបាលខេត្ត កំពត |

សមាសភាពអ្នកចូលរួម:

- មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ ចំនួន ១៩នាក់
- រាជធានីភ្នំពេញ:
  - កម្មវិធីអេដស៍រាជធានីភ្នំពេញ ចំនួន ០១នាក់

- មន្ទីរពេទ្យបង្អែក សម្តេចឪ ចំនួន ០២នាក់
- មន្ទីរពេទ្យបង្អែក មានជ័យ ចំនួន ០២នាក់
- មន្ទីរពេទ្យបង្អែក ចំការដូង ចំនួន ០២នាក់
- មន្ទីរពេទ្យបង្អែក ពោធិចិនតុង ចំនួន ០២នាក់
- មកពីគ្លីនិកសុខភាពសង្គម ចំនួន ០២នាក់
- មកពីសមាគមឈូកស ចំនួន ០១នាក់

- មន្ទីរសុខាភិបាលខេត្ត កណ្តាលៈ
  - កម្មវិធីអេដស៍ខេត្ត កណ្តាល ចំនួន ០១នាក់
  - មន្ទីរពេទ្យបង្អែក ជ័យជំនះ ចំនួន ០២នាក់
  - មន្ទីរពេទ្យបង្អែកស្រុក កោះធំ ចំនួន ០២នាក់
  - មន្ទីរពេទ្យបង្អែកស្រុក កៀនស្វាយ ចំនួន ០២នាក់
- មន្ទីរសុខាភិបាលខេត្ត តាកែវ
  - កម្មវិធីអេដស៍ខេត្ត តាកែវ ចំនួន ០១នាក់
  - មន្ទីរពេទ្យបង្អែក ដូនកែវ ចំនួន ០២នាក់
  - មន្ទីរពេទ្យបង្អែកស្រុក គិរីវង់ ចំនួន ០២នាក់
  - មន្ទីរពេទ្យបង្អែកស្រុក អង្គរកា ចំនួន ០២នាក់
- មន្ទីរសុខាភិបាលខេត្ត កំពតៈ
  - កម្មវិធីអេដស៍ខេត្ត ចំនួន ០១នាក់
  - មន្ទីរពេទ្យខេត្ត ចំនួន ០២នាក់
  - មន្ទីរពេទ្យបង្អែកស្រុក កំពង់ត្រាច ចំនួន ០២នាក់
- មន្ទីរសុខាភិបាលខេត្ត កំពង់ស្ពឺៈ
  - កម្មវិធីអេដស៍ខេត្ត ចំនួន ០១នាក់
  - មន្ទីរពេទ្យខេត្ត ចំនួន ០២នាក់
  - មន្ទីរពេទ្យបង្អែកស្រុក ឧដុង្គ ចំនួន ០១នាក់
  - មន្ទីរពេទ្យបង្អែកស្រុក គងពិសី ចំនួន ០២នាក់
- មន្ទីរសុខាភិបាលខេត្ត ព្រះសីហនុៈ
  - កម្មវិធីអេដស៍ខេត្ត ចំនួន ០១នាក់
  - មន្ទីរពេទ្យខេត្ត ចំនួន ០២នាក់
- មន្ទីរសុខាភិបាលខេត្ត កោះកុងៈ

- មន្ទីរពេទ្យបង្អែក ស្នាច់មានជ័យ ចំនួន ០២នាក់

- ការណែនាំឱ្យស្គាល់គ្នា និងធ្វើការបង្ហាញគោលបំណងនៃសិក្ខាសាលាដោយលោកវេជ្ជ. ខៃត ម៉ុត្រា មន្ត្រីផ្នែកថែទាំជំងឺអេដស៍

- លោក. ឿ្រន មឿ្រន បង្ហាញពី កាប្រើពាក្យនិងសំនួរក្នុងការផ្តល់ប្រឹក្សា:

- និយមន័យនៃការផ្តល់ប្រឹក្សា
- ការប្រើពាក្យនិងសំនួរក្នុងការផ្តល់ប្រឹក្សា

- លោក. ឈុំ ឆេងគង់ បង្ហាញករណីសិក្សានៅលើអ្នកជំងឺម្នាក់ភេទស្រីម្នាក់ដែលមានមានវិបត្តិផ្លូវចិត្តធ្ងន់ធ្ងរ ផ្ទុកមេរោគអេដស៍ ហើយបានមកទទួល ART នៅមន្ទីរពេទ្យសម្តេចឪ។

<u>ពេលរសៀល:</u>

- លោក. ឿ្រន មឿ្រន បានធ្វើការបង្ហាញពីមេរៀនស្តីពី ការឆ្លើយតបក្នុងការផ្តល់ប្រឹក្សា:

- ការឆ្លើយតបនេះវាទាក់ទងទៅនឹងការស្តាប់ឱ្យបានច្បាស់នូវអ្វី ដែលអតិថិជនបាននិយាយរួមទាំងសកម្មភាពផ្សេងៗផងដែរ។
- អ្នកផ្តល់ប្រឹក្សាត្រូវរកពាក្យនិយាយសម្តែងការឆ្លើយតបដោយមានការយល់ចិត្តអតិថិជនដោយមធ្យាបាយផ្សេងៗគ្នា
- ដោយទុកពេលឱ្យអតិថិជនកែតំរូវខ្លួនគេបើសិនជាមានកំហុសឆ្គង
- ចូរកុំព្រួយចំពោះការដែលអ្នកមិនមានការឆ្លើយតបបានត្រឹមត្រូវ ១០០% ត្បិតអតិថិជនអាចជួយកែគេបាន។
- អ្នកផ្តល់ប្រឹក្សាត្រូវបង្ហាញអតិថិយល់ឱ្យបានច្បាស់ថា អ្នកកំពុងព្យាយាមជួយគាត់ហើយ។

- លោកស្រី. ខេម៉ា សមាគមឈូកសបានធ្វើការបង្ហាញករណីសិក្សាស្តីពី ស្ត្រីម្នាក់មានHIV(+) ហើយបានមកទទួលសេវានៅសមាគម ឈូកស ហើយអ្នកជំងឺនោះជាជនជាតិវៀតណាមមិនចេះនិយាយខ្មែរមួយម៉ាត់សោះ។

- លោកស្រី. យាន សុម៉ាណា មកពីមន្ទីរពេទ្យខេត្តព្រះសីហនុ បង្ហាញពីករណីសិក្សាស្តីពីបុរសម្នាក់ កំពុងបានប្រើ ART ជួរទី ២ ហើយបានរៀបការជាមួយស្ត្រីម្នាក់ដែលបានដឹងពីស្ថានភាពគ្មានផ្ទុកមេរោគអេដស៍ទេ ហើយបុរសនោះចង់បានកូនក្នុងនាមជាអ្នកផ្តល់ប្រឹក្សាគួរធ្វើយ៉ាងណា?។

ថ្ងៃទី២ : ថ្ងៃទី ១៧ សីហា ឆ្នាំ ២០១១

<u>ពេលព្រឹក:</u>

- លោក. ឿ្រនមឿ្រន ធ្វើការបង្ហាញអត្ថបទមួយស្តីពីការប្រើពាក្យសំដីក្នុងការផ្តល់ប្រឹក្សា:

- អាចបកស្រាយពីនិយមន័យនៃការផ្តល់ប្រឹក្សា

- អាចបកស្រាយពីជំនាញនៃការស្តាប់ក្នុងការផ្តល់ប្រឹក្សា
- អាចបង្ហាញពីរបាំងផ្សេងៗ ស្តីពីការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍
- អាចកំណត់បានខ្លះៗពីការប្រើពាក្យរបស់អ្នកផ្តល់ប្រឹក្សាជាមួយអ្នកជំងឺ
- អាចបកស្រាយពីការប្រើពាក្យរបស់អ្នកផ្តល់ប្រឹក្សាជាមួយអ្នកជំងឺ

- ការបង្ហាញករណីសិក្សារបស់គ្លីនិកសុខភាពសង្គមដោយលោក.ខឹម ជម្ពូពល ស្តីពី អ្នកជំងឺម្នាក់បានប្រើ ART រួចហើយៗគាត់ជាប់គុកអស់រយៈពេល ១ឆ្នាំតើយើងជាអ្នកផ្តល់ប្រឹក្សាគួរធ្វើដូចម្តេច?

- ការបង្ហាញករណីសិក្សារបស់មន្ទីរពេទ្យបង្អែកខេត្ត កំពតដោយលោកស្រី. ស៊ុន ឌី ស្តីពីអ្នកជំងឺម្នាក់ បានប្រើ ART រួចហើយៗគាត់ប្រើឈប់ៗ។

- ការបង្ហាញករណីសិក្សារបស់មន្ទីរពេទ្យបង្អែកស្រុក កោះធំ ស្តីពី អ្នកជំងឺដែលប្រើ ART រួចហើយ ចាប់ពី CD4 Based line 135 ឡើងរហូតដល់ CD4= 449 ហើយធ្លាក់ចុះមកវិញមកនូវ CD4= 77 ។

ពេលរសៀលៈ

- រលឹកមេរៀនស្តីពីតួនាទីរបស់អ្នកផ្តល់ប្រឹក្សាដោយលោក. ឿើន ម៉ឿន

- ការបង្ហាញករណីរបស់មន្ទីរពេទ្យបង្អែកស្រុក គិរីវង់ដោយលោក. ឆេព សុជាត ស្តីពីអ្នកអ្នកជំងឺម្នាក់ភេទប្រុស បានចុះឈ្មោះក្នុងសេវា OI អស់រយៈពេល ២ឆ្នាំ ហើយCD4<350 ហើយគាត់មិនព្រមលេបថ្នាំ ART សោះ។

- ការបង្ហាញរបស់មន្ទីរពេទ្យអង្គរកាដោយលោក. ម៉ែ សំណាន លើករណីអ្នកជំងឺម្នាក់ដែលប្រើ ART តាំងពីឆ្នាំ ២០០៣ មកម្លេះ ហើយ CD4=326 (Mar,2009) ហើយបានចុះពីពេលនោះរហូតដល់ CD4=84 (Mar,2011)

ថ្ងៃទី៣ : ថ្ងៃទី ១៨ សីហា ២០១១

<u>ពេលព្រឹកៈ</u>

- ការបង្ហាញរបស់លោក. ឿើន ម៉ឿន ស្តីពី ការប្រកាន់ភ្ជាប់ភ្នួន ចំពោះការលេបថ្នាំ ART :
    - ពន្យល់ពីការប្រកាន់ខ្ជាប់ខ្លួនក្នុងការទំនាក់ទំនងដើម្បី ART
    - ពន្យល់ពីកត្តាសំខាន់ៗដែលប៉ះទង្គិចទៅលើការប្រកាន់ខ្ជាប់ខ្លួនចំពោះការព្យាបាលដោយ ART
    - ពិភាក្សាជាមួយអតិថិជនពីឧបគ្គនៃការប្រកាន់ខ្ជាប់ខ្លួនចំពោះការព្យាបាលដោយ ART
    - ជួយអ្នកជំងឺក្នុងការបង្កើតយុទ្ធសាស្រ្តកាតព្យាបាលការប្រកាន់ខ្ជាប់ខ្លួនឱ្យកាន់តែប្រសើឡើង
    - ជួយអ្នកជំងឺកំណត់បញ្ហា និងដោះស្រាយបញ្ហា

- ការបង្ហាញករណីសិក្សារបស់មន្ទីរពេទ្យបង្អែកជ័យជំនៈ ដោយលោក. ស្រ៊ា ពិសត្ថិ នៅលើករណីសិក្សាប្តីប្រពន្ធ ១គូ ដែលកំពុងប្រើប្រាស់ ART ក្រោយមកប្តីប្រើអំពើហឹង្សាមកលើប្រពន្ធ ដើម្បីឱ្យប្រពន្ធរបស់គាត់មកបើកថ្នាំជំនួនគាត់។

- ការបង្ហាញករណីសិក្សារបស់មន្ទីរពេទ្យខេត្ត តាកែវ ដោយលោកស្រី. ម៉ៃ យឹមឆាវី នៅលើករណីអ្នកជំងឺម្នាក់ជាស្រ្តីដែលមានជីវភាពខ្វះខាតខ្លាំងធ្វើឱ្យគាត់មកទទួលថ្នាំមិនទៀងទាត់។

- ការបង្ហាញករណីសិក្សារបស់មន្ទីរពេទ្យខេត្តកំពង់ស្ពឺដោយលោក. ង៉ាន់ ថន បុរសម្នាក់ប្រើ ART រួចហើយ តែគាត់ជាមនុស្សថ្លង់ ពិបាកក្នុងការផ្តល់ប្រឹក្សា។

<u>ពេលរសៀល:</u>

- ករណីអ្នកជំងឺដែលរកស៊ីនៅប្រទេសថៃ មិនបានមកទទួលថ្នាំទៀងទាត់ ហើយពួកគាត់បានធ្វើការផ្តាំផ្ញើឱ្យគេបើកថ្នាំឱ្យដោយលោក. ង៉ាត ពិទូ អ្នកផ្តល់ប្រឹក្សានៅមន្ទីរពេទ្យបង្អែក ស្អាងមានជ័យ។
- ចែកឯកសារសំរាប់ធ្វើការវាយតំលៃវគ្គដោយសិក្ខាកាមដែលបានចូលរួមទាំងអស់
- សង្ខេបសកម្មភាពការងារដែលបានធ្វើក្នុងរយៈពេល ៣ថ្ងៃកន្លងមក

<u>លទ្ធផលនៃការវាយតំលៃ:</u>

ការវាយតំលៃនេះធ្វើឡើងចំពោះអ្នកដែលចូលរួមក្នុងចំណោមសិក្ខាកាមទាំងអស់ដែលបានចូលរួម

| | | | | |
|---|---|---|---|---|
| | *វែងពេក* | *ល្មមសមរម្យ* | *ខ្លី* | *ខ្លីពេក* |
| ១. រយៈពេល | ៣ | ៣៣ | ៧ | |
| | *ល្អណា* | *ល្អ* | *មធ្យម* | *ខ្វះខាត* |
| ២. ទីកន្លែង | *១១* | *៣០* | *២* | |
| ៣. ការរៀបចំ | | | | |
| • អាកាសធាតុបន្ទប់ | ២ | ២៣ | ១៨ | |
| • ពន្លឺក្នុងបន្ទប់ | ២៥ | ១៦ | ២ | |
| • ការរៀបចំសំភារៈជំនួយ(LCD...) | ៥ | ៣០ | ៥ | ៣ |
| •អាហារសំរ៉ន់ និងភេសជ្ជៈ | | ១៤ | ១៥ | ១៤ |
| ៤. ឯកសារសំភារៈសិក្ខាកាម | ៥ | ២៧ | ១១ | |
| | *បានទាំងស្រុង* | *បានភាគច្រើន* | *ខ្លះៗ* | *គ្មាន* |
| ៥. តើសិក្ខាសាលានេះឆ្លើយតបទៅនឹង គោលបំណងរបស់វគ្គក្នុងកំរិតណា? | ៣៦ | ៧ | | |
| | *សំខាន់ណាស់* | *មិនសូវសំខាន់* | *គ្មានសំខាន់* | |
| ៦. តើសិក្ខាសាលានេះមានសារៈសំខាន់យ៉ាងណាចំពោះការងាររបស់អ្នក? | ៤៣ | | | |

៧. ការផ្តល់យោបល់ទៅលើអ្នកសំរបសំរួល:

- មានអាកប្បកិរិយាសមស្រប ទាំងកាយវិការ សំដីនិងមានទឹកមុខរីករាយ
- អ្នកសំរបសំរួលពន្យល់បានល្អ/និយាយច្បាស់
- ពេលខ្លះគ្រូសំរបសំរួលពន្យល់លឿនពេក
- គ្រូសំរបសំរួលឆ្លើយសំនួររបស់សិក្ខាកាមបានល្អ
- គ្រូសំរបសំរួលមានបទពិសោធន៍ល្អ

៨. ចំណុចសំខាន់អ្វីខ្លះដែលខ្វះខាតក្នុងសិក្ខាសាលានេះ?

- កិច្ចប្រជុំនេះមានរយៈពេលខ្លីពេក
- អាហារសំរ៉ន់ មិនគ្រប់គ្រាន់
- មិនអាចឆ្លើយតបភ្លាមៗ ចំពោះសំនួរមួយចំនួន
- មិនបាននិទានរឿងកំសាន្តខ្លីៗដើម្បីបន្ថយការងងុយ

៩. សំណូមពរផ្សេងៗ Ï

- សូមអោយមានប្រជុំ រៀងរាល់ ៦ខែម្តង
- សូមអោយមានអាហារសាមគ្គីពេលប្រជុំលើកក្រោយ
- ប្តូរទីតាំងប្រជុំទៅតំបន់ផ្សេង
- ចង់ដឹងព័ត៌មានពីប្រាក់ឧបត្ថម្ភ

៨. សេចក្តីសន្និដ្ឋាន:

កិច្ចប្រជុំនេះបានបញ្ចប់ដោយជោគជ័យនារសៀលថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១។ អ្នកចូលរួមទាំងអស់បានទទួលនូវចំណេះដឹងនិងបទពិសោធន៍រវាងមន្ទីរពេទ្យ និងមន្ទីរពេទ្យ ជាពិសេសទទួលបាននូវចំណេះដឹងថ្មីៗពីមជ្ឈមណ្ឌលជាតិ ដើម្បីយកទៅពង្រឹងការផ្តល់ប្រឹក្សានៅនិងកន្លែងបន្តទៅទៀត។

ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១១

បានឃើញ
ប្រធានមជ្ឈមណ្ឌលជាតិ

វេជ្ជ មាន_ឈីវុន

អ្នកធ្វើរបាយការណ៍

វេជ្ជ. ង៉ែត បុត្រា